# ឯកសារបញ្ជាក់ការពិតពីបទបញ្ញត្តិការពារអ្នកម៉ៅការឯករាជ្យ

អត្ថបទបកប្រែនៃឯកសារនេះ អាចទទួលបានតាមការស្នើសុំតាមរយៈ៖ (206) 256-5297 ។



បទបញ្ញាការពារអ្នកម៉ៅការឯករាជ្យរបស់ទីក្រុង សៀងថល (Seattle's Independent Contractor Protections Ordinance) តម្រូវអង្គភាពធានារ៉ាប់រងជួលអ្នកធ្វើការ ឱ្យផ្តល់អ្នកម៉ៅការឯករាជ្យនូវការជូនដំណឹងជាលាយលក្ខណ៍អក្សរមុនពេលចុះកិច្ចសន្យាហើយនិងនៅពេលទទួលការបង់ប្រាក់។ អ្នកម៉ៅការឯករាជ្យត្រូវតែបានទទួលការបង់ប្រាក់នៅឬមុនកាលបរិច្ឆេទកំណត់ទូទាត់ការបង់ប្រាក់ យោលក្រោមលក្ខខណ្ឌនៃកិច្ចសន្យា ក្រោមលក្ខខណ្ឌនៃការបញ្ចេញពតិ៌មានលម្អិតមុនចុះកិច្ចសន្យាឬក្នុងរយៈពេល 30 ថ្ងៃ។

## ការធានារ៉ាប់រង

### តើបុគ្គលិកណាខ្លះត្រូវបានធានារ៉ាប់រងដោយច្បាប់នេះ?

អ្នកម៉ៅការឯករាជ្យគឺជាអ្នកមានក្រុមហ៊ុនប្រកបមុខរបរដោយខ្លួនឯងដែលត្រូវបានអង្គភាពជួលមកធ្វើការដើម្បីផ្តល់សេវាកម្មប្តូរយកកំរៃ។ ច្បាប់នេះគឺសំដៅទៅលើអ្នកម៉ៅការឯករាជ្យទាំងអស់ ដោយមានករណីលើកលែង[1]មួយចំនួនដូចបានរាយនៅខាងក្រោម។

### តើក្រុមហ៊ុនណាខ្លះត្រូវបានធានារ៉ាប់រងដោយច្បាប់នេះ?

ច្បាប់នេះសំដៅទៅលើអង្គភាពជួលអ្នកធ្វើការ ដែលចូលរួមជាទៀងទាត់ក្នុងសកម្មភាពប្រកបអាជីវកម្មឬពាណិជ្ជកម្ម រួមទាំងអាជីវកម្មមិនស្វែងរកប្រាក់ចំណេញផងដែរ។

តើការងារអ្វីត្រូវបានធានារ៉ាប់រងដោយច្បាប់នេះ?

ការងារម៉ៅការត្រូវបានធានារ៉ាប់រងដោយច្បាប់នេះឬអត់គឺអាស្រ័យលើលក្ខណៈនៃសេវាកម្ម និងគុណតម្លៃនៃសេវាកម្ម។

**ប្រភេទនៃសេវាកម្ម**
- ការងារដែលធ្វើនៅទីក្រុង សៀងថល
- អង្គភាពជួលដឹង/មានហេតុត្រូវដឹងអំពីការងារដែត្រូវធ្វើនៅទីក្រុង សៀងថល

**$ តម្លៃនៃសេវាកម្ម**
- កិច្ចសន្យាច្រើនជាង ៦០០ ដុល្លារ
- កិច្ចសន្យាអាចបូករួមលើសពីមួយឆ្នាំ

[1] អ្នកម៉ៅការឯករាជ្យដែលមិនត្រូវបានធានារ៉ាប់រងដោយច្បាប់នេះគឺមេធាវី អ្នកបើកបររបស់ក្រុមហ៊ុនបណ្តាញធ្វើដំណើរ (ឧ. អ្នកបើកបររបស់ Uber និង Lyft) ក្នុងស្ថានការណ៍ដែលអ្នកម៉ៅការឯករាជ្យមានទំនាក់ទំនងជាមួយអង្គភាពជួលអ្នកធ្វើការមានកំណត់លើកិច្ចព្រមព្រៀងទាក់ទងនិងថ្លៃជួលកន្លែងប្រកបមុខរបរ (ឧទាហរណ៍ដូចជា អ្នកសម្អាងសក់ជួលតូបមួយកន្លែងនៅហាងសម្ផស្ស ជាដើម) និងអ្នកម៉ៅការឯករាជ្យផ្សេងទៀត ដែលត្រូវបានកំណត់ដោយច្បាប់របស់នាយកដ្ឋានដឹកនាំស្តង់ដាច្បាប់ការងារ។ សូមចុះឈ្មោះដើម្បីទទួល អត្ថបទព័ត៌មានពីការិយាល័យស្តង់ដារការងារនៃទីក្រុងសៀងថល (Seattle Office of Labor Standard, OLS) ឬចំពោះការធ្វើបច្ចុប្បន្នភាព សូមចូលមើលគេហទំព័ររបស់ OLS តាមរយៈ៖ www.seattle.gov/laborstandards។

**ក្រសួងត្រួតពិនិត្យស្តង់ដារច្បាប់ការងារប្រចាំទីក្រុងស៊ីឯថល**

*ឯកសារនេះផ្តល់ការពន្យល់អំពីច្បាប់។ សូមសម្គាល់ថា៖ ពត៌មានដែលផ្តល់ដោយក្រសួងត្រួតពិនិត្យស្តង់ដារច្បាប់ការងារ មិនមែនជាការទូន្មានផ្នែកច្បាប់ បង្កើតការសម្រេចចិត្តរបស់ភ្នាក់ងារ ឬបង្កើតសិទ្ធិរវាងមេធាវីនិងអតិថិជនជាមួយអ្នកអានទេ។ នេះមិនគួរយកមកប្រើជំនួសច្បាប់និងបទបញ្ញត្តិទេ។*

## តម្រូវការ

### តម្រូវការបង់ប្រាក់ឱ្យបានទៀងពេលវេលា

អង្គភាពជួលអ្នកធ្វើការ ត្រូវតែផ្តល់ "ការបង់ប្រាក់ឱ្យបានទៀងពេលវេលា" ដល់អ្នកម៉ៅការឯករាជ្យ ដូចខាងក្រោម៖

1) លក្ខខណ្ឌនៃកិច្ចសន្យា
2) លក្ខខណ្ឌនៃនៃការជូនដំណឹងជាលាយលក្ខណ៍អក្សរមុនធ្វើការ ឬ
3) ក្នុងរយៈពេល 30 ថ្ងៃ។

### តម្រូវការបញ្ចេញពត៌មានឱ្យបានដឹងឮ

អង្គភាពជួលអ្នកធ្វើការត្រូវតែផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីព័ត៌មានទូទាត់ប្រាក់ជាចំណុចៗ និងមុនធ្វើការដូចខាងក្រោមនេះទៅឱ្យអ្នកម៉ៅការឯករាជ្យដែលត្រូវបានធានារ៉ាប់រងទាំងអស់។ ទម្រង់គំរូនៃការជូនដំណឹងមានសម្រាប់ប្រើនៅលើគេហទំព័ររបស់យើងនៅទីនេះ។

1. តម្រូវការឱ្យជូនដំណឹងជាលាយលក្ខណ៍អក្សរមុនធ្វើការ

| | |
|---|---|
| ▪ *កាលបរិច្ឆេទ* | ▪ *មូលដ្ឋានបង់ប្រាក់* |
| ▪ *ឈ្មោះរបស់អ្នកម៉ៅការឯករាជ្យ* | ▪ *ច្បាប់ចែកលុយទឹកតែនិង/ឬថ្លៃផ្តល់សេវាកម្ម* |
| ▪ *ឈ្មោះអង្គភាពជួលអ្នកធ្វើការ + ព័ត៌មានទំនាក់ទំនង* | ▪ *ការចំណាយប្រាក់លើការងារនិងការចំណាយណាមួយដែលអង្គភាពជួលអ្នកធ្វើការត្រូវសងប្រាក់ចំណាយនោះមកវិញ* |
| ▪ *ការពិពណ៌នាអំពីការងារ* | ▪ *ការកាត់កង ថ្លៃសេវា ឬថ្លៃចំណាយ* |
| ▪ *ទីតាំងការងារ* | ▪ *កាលវិភាគនៃការទូទាត់បង់ប្រាក់* |
| ▪ *អត្រានៃការបង់ប្រាក់ខែ* | |

2. តម្រូវការឱ្យផ្តល់ព័ត៌មានទូទាត់ប្រាក់ជាចំណុចៗ

| | |
|---|---|
| ▪ *កាលបរិច្ឆេទ* | ▪ *របៀបចែក លុយទឹកតែ ប្រាក់ទូទាត់ និង/ឬ ថ្លៃសេវាកម្ម* |
| ▪ *ឈ្មោះរបស់អ្នកម៉ៅការឯករាជ្យ* | ▪ *មូលដ្ឋានបង់ប្រាក់* |
| ▪ *ឈ្មោះអង្គភាពជួលអ្នកធ្វើការ* | ▪ *ការទូទាត់សងថ្លៃចំណាយវិញដោយអង្គភាពជួលធ្វើការ* |
| ▪ *ការពិពណ៌នាអំពីសេវាកម្មដែលស្ថិតក្រោមការបង់ថ្លៃចំណាយ* | ▪ *ការទូទាត់បង់ប្រាក់សរុប* |
| ▪ *ទីតាំងនៃសេវាកម្មដែលត្រូវបង់ថ្លៃចំណាយ* | ▪ *ការកាត់កង* |
| ▪ *អត្រានៃការបង់ប្រាក់ខែ* | ▪ *ប្រាក់ខែក្រោយពីបានកាត់កងរួច* |

ក្រសួងត្រួតពិនិត្យស្តង់ដារច្បាប់ការងារ ប្រចាំទីក្រុងស៊ីឯថល

បេសកកម្មរបស់យើងគឺលើកកម្ពស់ស្តង់ដារការងារតាមរយៈការផ្តល់មតិយោបល់យ៉ាងលម្អិតពីសហគមន៍និងអាជីវកម្ម ការអនុវត្តយុទ្ធសាស្ត្រ និងការអភិវឌ្ឍន៍គោលនយោបាយប្រកបដោយភាពច្នៃប្រឌិត ដោយសន្យាផ្តល់នូវយុត្តិធម៌ជាតិសាសន៍និងសង្គម។

សេវាកម្មរបស់យើង
ការស៊ើបអង្កេតលើពាក្យបណ្តឹង
ការផ្សព្វផ្សាយដល់អាជីវករ
ជំនួយបច្ចេកទេសសម្រាប់អាជីវកម្ម
ធនធាននិងការណែនាំ
មានសេវាកម្មបកប្រែភាសា។
មានការសម្របសម្រួលផ្តល់ជូនជនពិការ។
មានផ្តល់សេវាកម្មដោយគឺឥតគិតថ្លៃ។

ព័ត៌មានបន្ថែម
ទូរស័ព្ទមកលេខ៖
(206) 256-5297
អ៊ីមែល៖ laborstandards@seattle.gov
ចូលមើល៖ seattle.gov/laborstandards

## ធនធាននានា

**ចំពោះពត៌មានតាមក្រោយទៀត សូមចូលមើលគេហទំព័ររបស់យើង ឬចុះឈ្មោះដើម្បីទទួលអត្ថបទពត៌មានរបស់យើងតាមរយៈ៖**
www.seattle.gov/laborstandards។

សូមអានបន្ថែមអំពីបទបញ្ញត្តិស្តីពីការការពារអ្នកម៉ៅការឯករាជ្យនៅទីនេះ៖
http://www.seattle.gov/laborstandards/ordinances/independent-contractor-protections-

**ក្រសួងត្រួតពិនិត្យស្តង់ដារច្បាប់ការងារប្រចាំទីក្រុងស៊ីឯថល**
*ឯកសារនេះផ្តល់ការពន្យល់អំពីច្បាប់។ សូមសម្គាល់ថា៖ ពត៌មានដែលផ្តល់ដោយក្រសួងត្រួតពិនិត្យស្តង់ដារច្បាប់ការងារ មិនមែនជាការទូន្មានផ្នែកច្បាប់ បង្កើតការសម្រេចចិត្តរបស់ភ្នាក់ងារ ឬបង្កើតសិទ្ធិរវាងមេធាវីនិងអតិថិជនជាមួយអ្នកអានទេ។ នេះមិនគួរយកមកប្រើជំនួសច្បាប់និងបទបញ្ញត្តិទេ។*